ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤១ ........អយក.សជណ

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្តផ្អាកសកម្មភាពអប់រំ និងកីឡា ក្រោយព្រឹត្តិការណ៍ ២៨ វិច្ឆិកា

ដើម្បីចៀសវាងការឆ្លងជំងឺកូវីដ-១៩ចូលក្នុងគ្រឹះស្ថានសិក្សា និងរីករាលដាលក្នុងសហគមន៍ ក្រសួងអប់រំ យុវជន និងកីឡាសូមដាក់ចេញនូវវិធានការដូចខាងក្រោម ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ព្រឹត្តិការណ៍សហគមន៍ ២៨ វិច្ឆិកា បានបញ្ចប់៖

១. ផ្អាករាល់សកម្មភាពជួបជុំ សិក្ខាសាលា និងកិច្ចប្រជុំ ដែលមានអ្នកចូលរួមលើសពី ២០ នាក់

២. ផ្អាកដំណើរការគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងគ្រឹះស្ថានសិក្សាឯកជន ជាបណ្តោះអាសន្ន ដោយបន្តការបង្រៀននិងរៀនតាមអនឡាញ

៣. ផ្អាករាល់ការហាត់ប្រាណ និងលេងកីឡា ដែលមានលក្ខណៈប្រមូលផ្តុំ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាល និស្សិត សិស្សានុសិស្សគ្រប់រូប ចូលរួមសហការអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១០រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០២០
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សមាគមគ្រឹះស្ថានឧត្តមសិក្សាកម្ពុជា
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  "ដើម្បីជូនជ្រាប និងសហការ"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានរដ្ឋបាល

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
✓អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh